# ការសម្ភាសរបស់ឈ្មោះ លោកយាយ ហាស អ៊ីម

**កៈ អ្នកសម្ភាស ហេង សុជីវី          ខៈ អ្នកត្រូវបានគេសម្ភាសឈ្មោះ ហាស អ៊ីម**

## ការសង្ខេបរបស់ឈ្មោះលោកយាយ ហាស អ៊ីម

លោកយាយហាស អ៊ីម មានអាយុ៩១ឆ្នាំ! ឆ្នាំម្សាញ់ លោកយាយមានអាយុបានវែងដោយសារតែគាត់អត់ស៊ូវឈឺ! អត់មានជំងឺអីធ្ងន់ធ្ងរ!សព្វថ្ងៃលោកយាយបានកាន់សីល៥ ជួយមើលចៅ នៅចាំផ្ទះ និងអាច កាប់អុសដើមតូចៗ បាន ហើយគាត់មានការចង់ចាំនៅបានល្អ។ ការសម្ភាសនៅក្នុងឆ្នាំ២០១៩!លោកយាយ ហាស អ៊ីម មានទីលំនៅក្នុងភូមិទឹកចេញ ឃុំព្រៃកក្រពៅ ស្រុកកងមាស ខេត្តកំពង់ចាម។ កាលពីមុនលោកយាយអត់មានបានរៀនសូត្រនោះទេ ដល់ពេលក្រោយមកបានរៀបការមានប្តីដោយសារតែចាស់ទុំជាអ្នករៀបចំទុកដាក់អោយដោយស្របច្បាប់នៅអាយុ២២ ជាមួយនឹងស្វាមីអាយុ២៥ឆ្នាំ។លោកយាយបានមានកូនបាន ៣នាក់ តែស្វាមីរបស់លោកយាយបានស្លាប់នៅអាយុ៦០ជាង ហើយកូនៗរបស់លោកយាយក៏បានស្លាប់ដែរ នៅសល់តែកូនស្រី១នាក់ ដែលមានចៅមានជំងឺជាបន្ទុក ។លោកយាយ ហាស អ៊ីម មានបងប្អូនបាន៦នាក់ស្រី៣និងប្រុស៣នាក់ លោកយាយជាកូនពៅគេ តែក្រោយមកដល់ពេលឥឡូវបងប្អូនរបស់លោកយាយបានស្លាប់អស់នៅតែលោកយាយតែម្នាក់ឯង។លោកយាយ ហាស អ៊ីម មានសេចក្តីប្រាថ្នា ព្រោះខ្លួនចាស់ដងទឹកអត់រួចពឹងកំលាំងកូន ចឹងចង់បានម៉ាស៊ីនប៊ូមទឹកសំរាប់បន្ថយកំលាំងកូនស្រីគាត់បានខ្លះ និងប្រាថ្នាចង់មានកន្លែងកប់សពខ្លួននៅខាងមុខផ្ទះ និងបានទិញដីចាក់បន្ថែម ព្រោះអីចង់ទៅណាក្រៅពីកន្លែងផ្ទះរបស់លោកយាយបន្ទាប់ពីជីវិតនេះ!

កៈ ចាំ! ជាដំបូវសូមជំរាបសួរលោកយាយ!

ខៈ ចាំ!

កៈ ចា! លោកយាយនៅក្នុងថ្ងៃនេះ ចៅមានឪកាសដើម្បីមកសម្ភាសដល់លោកយាយហើយថ្ងៃសម្ភាសគឺជាថ្ងៃទី៣ ខែ៤ ឆ្នាំ២០១៩ ហើយចៅជាអ្នកសម្ភាសមានឈ្មោះថាហេងសុជីវី ហើយដល់ពេលលោកយាយវិញតើលោកយាយមានឈ្មោះអ្វីគេដែរ?

ខៈ ខ្ញុំឈ្មោះយាយអ៊ីម! អ៊ីម!

កៈ ហើយឈ្មោះហ្នឹង មានបានត្រូវជាមួយនឹងនាមត្រកូល មានបានត្រូវជាមួយនឹងអត្តសញ្ញាណប័ណ្ណ?

ខៈ ហាស អ៊ីម។

កៈ ចាំ!

ខៈ ឪពុករបស់ខ្ញុំមានឈ្មោះថា តាហាស!

កៈ ចាំ! ហើយលោកយាយមានបានដឹងថាឈ្មោះនេះមានអត្ថន័យយ៉ាងណាដែរលោកយាយបានជាគាត់បានដាក់អោយណា?

ខៈ មានអត្ថន័យយ៉ាងម៉េចនោះទេ គឺថាមានឈ្មោះតែ១ហ្នឹងតែម្តង។

កៈ ចាំ!

ខៈ ចា!

កៈ ហើយចឹងតើឈ្មោះហ្នឹងអ្នកណាជាអ្នកដឹងឈ្មោះហ្នឹងអោយដល់លោកយាយ?

ខៈម្តាយរបស់ខ្ញុំនិងឪពុករបស់ខ្ញុំជាអ្នកដែលបានដាក់។

កៈ ចាំ! លោកយាយអឺអាយុប៉ុន្មានហើយនៅក្នុងឆ្នាំហ្នឹង?

ខៈ ខ្ញុំបានអាយុ៩១ហើយនៅក្នុងឆ្នាំហ្នឹងណា។

កៈ ចាំលោកយាយមានអាយុវែងម៉ែនទែន។

ខៈ ចាំ!

កៈ ចាំចឹងសុខភាពអីយ៉ាងម៉េចដែរ នៅរាល់ថ្ងៃហ្នឹងយាយ?

ខៈ លំបាក! ធ្វើមិនកើត កូនធ្វើតែឯង ចិញ្ចឹមជាមួយនឹងម្តាយ! ហើយនៅពេលកាលតានៅនោះខ្ញុំវាមិនសូវជាលំបាកនោះទេណា ដល់ពេលតាងាប់ទៅ ខ្ញុំលំបាកណាស់ លំបាកចិញ្ចឹមកូននុងណា។ ចិញ្ចឹមម្តាយផង! ចិញ្ចឹមចៅនោះផង ធ្វើការមិនកើតនោះទេ ឆ្កួត! វាមិនទៅឆ្កួតរលេរលូនោះទេគ្រាន់តែវាធ្វើអីមិនបានកើតនោះទេ វានិយាយមិនច្បាស់។

កៈ ហឹម!

ខៈ ចាំ! វាមិនមែនថា!ឆ្កួតនោះទេ វាបាននៅតែផ្ទះនុង តែថាដល់ពេលកូននុងវាឆ្កួតចឹងទៅគឺថាវាដើរធ្វើអីវាអត់បានកើត ចឹងម្តាយវានុងបានចិញ្ចឹមទាំងខ្ញុំ និងកូនរបស់វានុង តែខ្ញុំមិនមែននេះបើសិនជាខ្ញុំនេះ មិនត្រូវបានពិបាកចឹងបើសិនជាតារបស់ខ្ញុំគាត់នៅរស់ តែថាគាត់បានខូចតាំងពីពេលគាត់នៅបានអាយុ៧៦ម៉េសណា។

ក៖ហឹម!

ខ៖តារបស់ខ្ញុំណា! តាមួននុង។

ក៖ ហឹមលោកយាយហើយលោកយាយមានបាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងដែលបានកើតដែរឬទេលោកយាយ?

ខ៖ ចាំកើត! ខ្ញុំបានកើតនៅខែផល្គុន អឺ....បើសិនជាថ្ងៃនោះគឺបានភ្លេចទាំងថ្ងៃបាត់ទៅហើយនេះ គឺថ្ងៃព្រហស្បត្តិ៍។

ក៖ ហឹម!

ខ៖ ចាំ!

ក៖ ហើយចុះឆ្នាំ?

ខ៖ ចាំ!ខ្ញុំកើតនៅក្នុងឆ្នាំម្សាញ់ ! ម្សាញ់នុងគឺយូរហើយណាឆ្នាម្សាញ់ហ្នឹង។

ក៖ ចាំ! លោកយាយចឹងរាល់តែថ្ងៃហ្នឹងលោកយាយបាននៅផ្ទះមែននៅឯភូមិឃុំណាដែលលោកយាយ?

ខ៖ នៅផ្ទះមិនមែនបានធ្វើអីកើតនោះទេ។

ក៖ ចាំ!

ខ៖ មើលតែកូន ដាំតែបាយអោយហូបនោះទេចៅ។

ក៖ ហឹម

ខ៖ គ្មានបានទៅធ្វើអីកើតនោះទេ។

ក៖ ចាំ! នៅទីនេះគេបានហៅថាភូមិឃុំអីគេដែរលោកយាយ?

ខ៖ នៅក្នុងភូមិទឹកចេញ! ឃុំហោស?

ក៖ ភូមិឃុំ?

ខ៖ ឃុំព្រែកក្របៅ!

ក៖ ចាំដល់ពេលភូមិគឺភូមិទឹកចេញ?

ខ៖ ភូមិខ្ញុំនៅគឺភូមិទឹកចេញ!

ក៖ ចាំស្រុកកងមាស ខេត្តកំពង់ចាមលោកយាយ?

ខ៖ ចាំ! ស្រុកកងមាសខេត្តកំពង់ចាម ឃុំព្រែកក្របៅ ។

ក៖ ចាំ! ស្រុកកំណើតរបស់លោកយាយនៅទីនេះតែម្តងឬក៏យ៉ាងណាដែរ?

ខ៖ ស្រុកកំណើតរបស់ខ្ញុំគឺនៅឯទីនេះតែម្តង។

ក៖ ចាំ!

ខ៖ កាលពេលការរបស់ខ្ញុំនោះគឺថាខ្ញុំបាន ដីតាខ្ញុំបានចែកអោយនៅឯទីនេះតែម្តង មកនៅហ្នឹងតែម្តង។

ក៖ ចាំ!

ខ៖ ចាំ!

ក៖ ហើយដល់ពេលចឹងរស់នៅហ្នឹងយូរហើយតាំងពីពេលជីដូនជីតារបស់លោកយាយបានរស់នៅតមករហូត?

ខ៖ ខ្ញុំបានមួយកាលរបស់ខ្ញុំបានតាំងពីពេលកើតមកគឺនៅទីនេះតែម្តង ។

ក៖ ហឹម

ខ៖ ដល់ទៅពេលខ្ញុំបានកូនមកក៏ខ្ញុំបានរស់នៅលើទឹកដីហ្នឹងទៀត ហើយខ្ញុំបានទៅនៅខាងទឹកដីទីនេះបានមួយសារហើយខ្ញុំបានមកបានមានកូនបាន៣នាក់ហើយបានជាខ្ញុំបានមកនៅទីហ្នឹង។

ក៖ ហឹម!

ខ៖ ចាំកាលពីដើមខ្ញុំបានមានកូនបាន៣នាក់ហើយខ្ញុំបាននៅខេត្ត នៅខាងព្រៃឈរណា មានប្តីហើយទៅក៏បានទៅនៅខាងព្រៃឈរវិញ គឺថាបងរបស់ខ្ញុំគាត់បានហៅអោយមកនៅទីនេះវិញ គាត់បានប្រាប់ថា នេះយកទៅគឺអញគ្មានកូន ហើយចឹងហាង់យកទៅ។

ក៖ ហឹម!

ខ៖ចាំ!

ក៖ លោកយាយចឹងជីវិតរបស់លោកយាយកាលពីមុនមកតើលោកយាយបានឃើញផ្ទះរបស់លោកយាយមានសភាពយ៉ាងណាដែរ?

ខ៖ប្រាប់ថាម៉េចចៅ?

ក៖ ផ្ទះរបស់លោកយាយកាលពីជំនាន់ដើមណាលោកយាយ?

ខ៖ ផ្ទះរបស់ខ្ញុំហោស?

ក៖ ចាំ

ខ៖ ផ្ទះស្លឹក! គឺជាផ្ទះស្លឹក ផ្ទះការតាំងតូចល្មមនោះទេ! ម្ដាយក្មេងបានចែកអោយដែរ មិនមែនបានធ្វើដោយខ្លួនឯងនោះទេ។

ក៖ហឹម

ខ៖ ចាំ!ហើយខ្ញុំទើបតែបានមានការកសាងមកនេះទើបពេលកំណើតកូនពៅរបស់ខ្ញុំ បានធ្វើនេះ ចឹងបានទំរាំតែបានផ្ទះប៉ុណ្ណឹងទៅ តែមិនដឹងថាទៅរកអីនោះទេចៅអើយ។

ក៖ លោកយាយកាលពីជំនាន់មុននុងលោកយាយឪពុកម្ដាយរបស់លោកយាយមានឈ្មោះអ្វីដែរ?

ខ៖ ឪពុករបស់ខ្ញុំមានឈ្មោះថា តាហាស ហើយម្ដាយរបស់ខ្ញុំឈ្មោះថា យាយអ៊ឹម។

ក៖ ចឹងតើលោកតាមានប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមគ្រួសារ?

ខ៖ គាត់ហ៎!គាត់គឺធ្វើស្រែចឹងដែរ ដល់ពេលគាត់បានចាស់ចឹងទៅ គាត់រកអីមិនបានកើតចឹងខ្ញុំក៏រកអីដើម្បីចិញ្ចឹមគាត់ ម្ដងទៅ ទាល់តែពេលគាត់បានខូចចឹងទៅ! ចឹងបានធ្វើបុណ្យអីអោយដល់គាត់ បានធ្វើបុណ្យបញ្ចុសគាត់ចឹងទៅណា។ចាំបានតែប៉ុណ្ណឹងនោះទេចៅ!

ក៖ ចាំចឹងគាត់ទាំង២នាក់ជាមនុស្សបែបណាដែរលោកយាយ?

ខ៖ ស្លូតណាស់ ខ្មោចម្ដាយឪពុកខ្ញុំគាត់ស្លូត។ ម្ដាយរបស់ខ្ញុំស្លូតណាស់ បងប្អូនណាក៏មិនចេះខុសដែរ។

ក៖ អូ! ចាំ! ហើយចុះកើតទាន់ជីដូនជីតារបស់លោកយាយទាំងខាងម្ដាយនិងខាងឪពុករបស់លោកយាយដែរអត់?

ខ៖ ខ្ញុំបានកើតទាន់កុង កាលនុងខ្ញុំបាននៅស្វាតាហែន ខ្ញុំបាននៅ បានមានស្រុកកំណើតរបស់ខ្ញុំនៅស្វាតាហែន នៅស្វាតាហែនយើងនេះណា។

ក៖ ចាំ!

ខ៖ នៅកងមាសយើងនេះដែរ ចឹងគឺនៅស្វាតាហែននៅទាន់ក៏ប៉ុន្តែយើងគឺមិនបានមានស្គាល់ឈ្មោះរបស់គាត់នោះទេ គឺថាគាត់ជាជនជាតិចិនឆៅ។

ក៖ ហឹម!

ខ៖ តារបស់ខ្ញុំនុង គឺគាត់ជាជនជាតិចិនឆៅ ប៉ុន្តែមកដណ្ដឹងនៅស្រុកយើងហ្នឹងបានមករកស៊ីៗមក រែកតែការចែល២មកនុងណា កាលនុងខ្ញុំមានបានទាន់តែបានគាត់ឃើញប្រាប់ខ្ញុំថាចឹងណា។

ក៖ ចាំ!

ខ៖ ចឹងនៅកាលនុងអោយតែបានលឺម៉ាត់ចិនលូឡា!ៗនោះខ្ញុំខ្លាចហើយរត់ទៅពួនហើយ ខ្លាចខ្លាចចិនចាប់ដាក់នៅក្នុងការចេល ចឹងថាចាស់កាលពីដើមនោះចោតណាស់ចៅអើយ! មនុស្សកាលពីដើមនោះ។

ក៖ ហឹម!ហើយចឹងជីដូនជីតារបស់យាយមានឈ្មោះអីគេខ្លះទាំងខាងឪពុកនិងខាងម្ដាយរបស់យាយ?

ខ៖ យាយតារបស់ខ្ញុំឈ្មោះយាយ ទាវខាងខ្ញុំណា ហើយឪពុកឈ្មោះ ... ខ្ញុំភ្លេចហើយព្រោះអីវាយូរដែលហើយចៅ វារង្វេងដែរណា ចាស់ហើយណាតាឈ្មោះតា.... ហឹម រត់នៅចុងៗមាត់! បើសិនជាយាយវិញគឺខ្ញុំបានដឹងថាលោកយាយ ទាវ។ ចាំ!

ក៖ ចាំ! ហើយគាត់ទាំងអស់គ្នាជាមនុស្សបែបណាដែរលោកយាយ?

ខ៖ គាត់ទាំងអស់គ្នាជាមនុស្សស្លូតៗ កូនចៅរបស់ខ្ញុំគ្មានអ្នកណាបានទៅឃោរឃៅអីនោះទេ។

ក៖ ចាំហើយទៅគាត់និយាយភាសាខ្មែរឬក៏ជាភាសាចិនដែរយាយ?

ខ៖ តានុងហេស?

ក៖ចាំ

ខ៖ គាត់និយាយខ្មែរ តែថាគាត់និយាយមិនបានច្បាស់នោះទេ គឺគាត់និយាយបានប៉ៃលាំមៗ។

ក៖ ហឺសៗ!

ខ៖ ចាំ! ហើយខ្ញុំបានកើតមក ឪពុករបស់ខ្ញុំគាត់ខ្មែរសុត ឪពុករបស់ខ្ញុំនុង ១ពូជរបស់ខ្ញុំនុងគឺថាខ្មែរសុតទាំងអស់ទេ គ្មានចិននោះទេ។

ក៖ ហឹម!

ខ៖ មានតែខាងទន្លេកុងរបស់ខ្ញុំ១នាក់នុង គ្មានអ្នកណាទៀតនោះទេ។ចាំ!

ក៖ ចាំលោកយាយ! ហើយទៅជីដូនជីតារបស់លោកយាយគាត់មានដែលបានប្រាប់លោកយាយ យ៉ាងម៉េចខ្លះដែរ?

ខ៖ ប្រាប់យ៉ាងម៉េចដែរចៅ?

ក៖ ដូចថាជាដំបូន្មានណាលោកយាយ គាត់មានដែរបានធ្លាប់បានទូន្មានប្រាប់ដល់លោកយាយថាយ៉ាងម៉េចខ្លះណាដែរ កាលពីសម័យនៅជំនាន់មុន?

ខ៖ បានប្រាប់ថារឿង ធ្វើស្រែនុងគឺបានធ្វើតែស្រែអោយតែខ្ញុំនុងដែរចឹងណា គាត់បានថាកូនណាបានធ្វើវាចេះ ថាស្រែនុងធ្វើចេះធ្វើចុះ ថាគ្មានបានទៅភ្ជួររាស់អីគេនោះទេ គ្មានបានមានម៉ាស៊ីនអីនឹងគេនោះទេ កាលនុងវេទនាណាស់ចៅអើយ! ប្រវត្តិ។

ក៖ ចាំចឹងចុះឪពុកម្ដាយរបស់លោកយាយវិញតើគាត់មានដែលបានទូន្មានដល់លោកយាយថាយ៉ាងម៉េចដែរទៅអត់កាលពីជំនាន់មុនណា?

ខ៖ គាត់បានប្រដៅតែថាអោយកូនបានល្អអោយតែកូនបានខិតខំ អោយកូនប្រឹង កុំអោយកូនបានរលីរលៀស ដល់ពេលចឹងទៅ ខ្ញុំនេះក៏បានចេះតែស្ដាប់ម្ដាយទៅ។

ក៖ ហឹម!

ខ៖ ចឹងក៏បានតាមម្ដាយទៅ! ដល់ពេលធំឡើងទៅ! មានគេចង់បានខ្ញុំ ហើយចឹងតារបស់ខ្ញុំគាត់បានមកដណ្ដឹងខ្ញុំទៅ គាត់បានសួរថាតើកូនឯងបានយកដែសមនុស្សហ្នឹង ខ្ញុំថា ប្រកែកហើយចឹងយាយនុងបានប្រាប់ថាបើសិនជាអោយនោះគឺអោយទៅព្រោះអីតានុងគាត់ស្លូតណាស់! ម្ដាយក្មេករបស់ខ្ញុំនុងណា។

ក៖ ចាំ!

ខ៖ គាត់ថា កូនប្រុសរបស់គាត់ស្លូតដែរចឹងហើយបានមកដណ្ដឹងខ្ញុំ រួចទៅក៏បានតានុងហើយដណ្ដឹង ប៉ុន្ដែខ្ញុំកើតទាន់ជំនាន់ការ មានតែភ្លេងនោះទេ គ្មានអី គ្មានមេក្រូ គ្មានអីនោះ ចាំគ្មានទេ គ្មានទេកំសត់ណាស់ចៅ ខ្ញុំបាននៅតាំងពីស្រុកនៅកំសត់ កាលចាស់ៗនៅពីដើមម៉េស ដែរខ្ញុំបានទាន់។

ក៖ហឹមលោកយាយ ចឹងកាលពីនៅក្នុងជំនាន់នុង ឪពុកម្ដាយរបស់លោកយាយមានបានឲ្យលោកយាយរៀបចំអោយមានស្វាមីនុងនៅអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំហេស! ខ្ញុំបាននៅអាយុបាន២២បានជាខ្ញុំបានរៀបការ។

ក៖ ហឹម! ហើយចឹងលោកយាយបានរៀនសូត្រអីដល់កំរិតណាដែរកាលពីសម័យមុន?

ខ៖ ខ្ញុំអត់មានបានរៀនអីនោះទេចៅ! កាលនុងដើរមកជិតនៅអាប៉ុលនេះ គេបានអោយរៀននៅខាងសហាគមន៍បានធ្វើរោងនៅក្នុងព្រៃនោះ មានក ខ បាន១ចប់ចឹង ហើយបានមកដល់ពេលឥឡូវនេះ គឺបានភ្លេចអស់ហើយចៅអើយគ្មានបានអីនោះទេ! អោយតែថាបានគិតតែពីការងារដល់តែថាបានរកតែនុងចឹងទៅក៏បានភ្លេចអស់ឯនុងចឹងទៅ។

ក៖ ចាំ!

ខ៖ ចាំ

ក៖ ហើយមានកាលនៅពីពេលកាលមុននុងមានក្ដីស្រមៃថានៅពេលធំឡើងចង់ធ្វើអីដែរឬទេដូចជាមុខរបរគ្រូបង្រៀនឬក៏អ្វីចឹងណា ជាអ្នកកាត់ដេរឬក៏ជាអី?តើយាយមានក្ដីស្រមៃថាបានមានធ្លាប់ប្រាថ្នាអីដែរឬទេកាលពីនៅពីក្មេងទេ?

ខ៖ ប្រាថ្នាម៉េច បើសិនជាកាលនៅពីជំនាន់របស់ខ្ញុំនោះវាអត់មានអាហ្នឹង គ្មាននោះទេ កូនគេក៏ដូចជាកូនរបស់យើង គ្មានអ្នកណាគេបានគិតតែដេរអីនោះទេ កាលនុងគិតតែរឿងពេញញាស់ដឹងធំឡើង អោយរៀនបានបន្តិចបន្តួចនុង បានចេះស្នូងចេះដក បានប្រដៅកូនអោយធ្វើស្នូងធ្វើដកអីតែម្ដង ទាំងគេទាំងខ្ញុំនេះចឹងតែម្ដង។

ក៖ ហឹមចាំលោកយាយ!

ខ៖ នេះកាលជំនាន់យូរហើយ!

ក៖ ហឹម លោកយាយបានឆ្លងកាត់ជំនាន់អីគេខ្លះដែរចឹង?

ខ៖ ខ្ញុំឆ្លងកាត់នុង គឺបានឆ្លងកាត់នៅក្នុងជំនាន់នុង គឺបានឆ្លងកាត់ជំនាន់ខ្មែរក្រហម បាន១សារទៅភ័យ ព្រោះអីគេបានប្រមូលភូមិស្រុកនោះ។ចាំហើយអានេះហ្នឹងបាន១សារទៀតអីចឹងទៅ ដល់ពេលនេះបាន១សារទៀត មកស្អី គឺមកនៅជំនាន់លន់ ណល់ គេបានទំលាក់កប៉ាល់ហោះនោះគឺហោះអើយហោះ! បានហោះទាំងវ៉ូង ហ្នឹងក៏ខ្លាចដែរ ខ្ញុំមិនហ៊ានដែលបានចេញពីវាលនោះទេ ខ្ញុំខ្លាចណាស់ចៅអើយ!។

ក៖ ហឹម!

ខ៖ ចាំ!

ក៖ ហឹម ចាំ!

ខ៖ ខ្លាច រួចផុតពីនុងមកបានមកដល់អាពតនុងណា ដល់ពេលជំនាន់អាពតនោះមកទៀត តារបស់ខ្ញុំនុងគឺថា គាត់បានជីករន្ធដៅអោយ គឺថាបានជីករន្ធដៅនៅត្រង់ផ្ទះ រន្ធដៅច្រក ទៅមើលគឺថាគេបានមានរន្ធដៅសំរាប់ច្រកត្រង់សុកណា។ វេទនាណាស់ ដូចជាកូននេះអីកាលនឹងខ្ញុំបាននាំចូលទៅក្នុងរន្ធដៅ បានដឹកដៃកូនបាន២នាក់ កាលនុងកូនគេបាននៅតូចៗ ចឹងក៏បានចូលនៅក្នុងរន្ធដៅទៅ! កាលនុងគឺថាវាបានវេទនាណាស់ខ្ញុំ។

ក៖ ហឹម!ចឹងនៅកាលនុងតើយាយមានបានអាយុប៉ុន្មាន?

ខ៖ ចាំ!

ក៖ កាលពីនៅក្មេងៗហេសយាយ?

ខ៖ ចាំកាលនុងហេស?

ក៖ ចាំ!

ខ៖កាលនុងអេស! កាលនុងខ្ញុំបាននៅទើបតែអាយុបាន៥៨។

ក៖ ហឹប! តែគេបានទើបតែបានទំលាក់គ្រាប់ទេយាយណំា?

ខ៖ ហ្នឹងហើយគេបានទើបតែទំលាក់គ្រាប់ឡើង។

ក៖ ចាំលោកយាយ ចឹងនៅកាលនុង តើពេលនុងលោកយាយបានមានកូនប៉ុន្មានដែរហើយ?

ខ៖ កូនរបស់ខ្ញុំហ៎! កូនរបស់ខ្ញុំមាន៦នាក់ មានស្រី៣ហើយនិងប្រុសបាន៣នាក់។

កៈ ចាំហើយចុះយាយបានអោយគាត់រៀនសូត្រអីបានដល់កំរិតណាដែរ?

ខៈ អោយម៉េចដែរចៅ?

កៈ រៀនសូត្រយាយដល់កំរិតណាដែរ?

ខៈ រៀនសូត្របើសិនជាមីនេះមិនដឹងថារៀនបានត្រឹមថ្នាក់ទីប៉ុន្មាននោះទេ ខ្ញុំអត់បានចាំ។ (លោកយាយគាត់បានចង្អុល ទៅកូនរបស់គាត់ដែលនៅជាមួយនឹងគាត់រាល់ថ្ងៃ។) បើសិនជាមួយទៀតបាននៅចាំ គឺបានរៀនដល់ត្រឹមថ្នាក់តី៥ហើយណា កាលនុងគឺថាបាននៅថ្នាក់កុមារដ្ឋាននោះទេណា ចឹងអានុង មិនដឹងថាបានរៀនដល់ត្រឹមថ្នាក់ទីប៉ុន្មានបើសិនជាខ្ញុំនោះអត់សូវបានចេះអក្សរនោះដែរ ហើយបើសិនជាអាប្រុសនោះវិញគេបានរៀនបានច្រើន ហើយក្រៅពីហ្នឹងគេបានងាប់អស់ហើយទៅណាចៅ។

កៈហឹម! ចឹងកូនប្រុសកូនរបស់លោកយាយបានស្លាប់អស់ហើយចឹង?

ខៈ ឆ្នាំម្សាញ់ដូចជាឆ្នាំរបស់ខ្ញុំដែរ។

កៈចាំ!

ខៈ អាពៅគេនុងណា អាបងគេឆ្នាំឆ្លូវ។

កៈ ហឹម ចឹងលោកយាយកូនទាំង៦នាក់នុង...

ខៈ កូនមាន៦នាក់ប្រុសបាន៣ហើយស្រីបាន៣។

កៈ ចាំ!

ខៈ បានងាប់អាពត បានយកអស់៣ទៅ បាននៅសល់៣ ។

កៈ ហឹម!

ខៈ បាននៅសល់ត៣ ដល់ពេលក្រោយមកវាបានឈឺដោយសារតែខ្លួនឯងចឹងទៅអស់២នាក់ទៀត ចឹងនៅសល់កូនតែ១នាក់។

កៈហឹម!

ខៈ ចឹងគឺវេទនាណាស់ចៅ!

កៈហឹម!

ខ៖ គេបានអូសកូន អូសចៅបានយកទៅវ៉ៃចោលហើយបាននៅកូនតែ១ ហើយចៅបានឈឺ! ឈឺងាប់ៗ អស់២នាក់ទៀតចឹងបាននៅតែ១នាក់ហ្នឹង។

ក៖ ហឹម!

ខ៖ ចឹងបាននៅម្នាក់តែបានចិញ្ចឹមខ្ញុំដល់ពេលរាល់តែថ្ងៃហ្នឹង មានតែ១នាក់ហ្នឹង ។

ក៖ ហឹម!

ខ៖ ហើយបានចិញ្ចឹមខ្ញុំហើយបានថែមអាកូន១នុងធ្វើអីមិនបានកើតនោះទេ គឺថាបានលេលឺលៗ និយាយនោះក៏វាមិនបានច្បាស់ៗ វាបាននិយាយមិនច្បាស់ បានច្បាស់តែ១ម៉ាតៗដែរចេះតែចឹងទៅ ដល់ពេលតែថាទឹកអណ្តូងនោះដងវាមិនបានមុជនោះផង គឺថាបានវាមកដងបំរើសឹងរាល់តែថ្ងៃ ខ្ញុំគឺថាបានកូនដង។

ក៖ ចាំគាត់មានអាយុប៉ុន្មានហើយ?

ខ៖ កូនរបស់ខ្ញុំហោស?

ក៖ អឺ ចៅរបស់យាយ?

ខ៖ ចៅខ្ញុំដែលថាមិនបានដឹងអីនុងហោស?

ក៖ ចាំ!

ខ៖ មានអាយុបាន១៦ទៅ១៧ឆ្នាំហើយ មិនអាយុតិចនោះទេ តែមិនបានដឹងអីនោះទេ។

ក៖ តើគាត់មានដែលបានធ្លាប់មានបញ្ហាអីមែនលោកយាយ ព្រោះអីគាត់បានកើតមកចឹងមក ឬក៏គាត់បានធ្លាប់ដួល?

ខ៖ កើតមកនោះអត់មានអីនោះទេ កើតមកពីដំបូង ពេលវានៅពីតូចខ្ញុំស្មានតែវាមិនចេះនិយាយ ចេះនិយាយអីកើត កាលនៅពីតូច ព្រោះអីកាលនៅពីតូចនោះគឺថាវាបានចេះនិយាយអីបានតិកតក់ៗអីចឹងគឺថាខ្ញុំស្មានតែវាចេះនិយាយអីកើត ដល់ពេលវាធំឡើងវាចេះតែនិយាយទៅៗ ខ្ញុំក៏បានចេះតែចិញ្ចឹមចៅទៅ បានដើរទៅតាមចៅចឹងទៅ បានចិញ្ចឹមចៅហើយមិនហ៊ានបានដើរចោលនោះទេ ព្រោះអីចៅរបស់យើងស្រីណា។

ក៖ ហឹម

ខ៖ ខ្ញុំនេះក៏លំបាកដែរចៅអើយៗ ដើរតាមចៅ មិនបានហ៊ានចិញ្ចឹមចៅដែលលេលើសអញ្ចឹង ណា បើសិនជាខ្ញុំលែងទៅ វាមានកូន មានចៅជាមួយនឹងអ្នកណាទៅ ហើយបានចិញ្ចឹមកូនហ្នឹងទៀតហើយ  ចឹងខ្ញុំខ្លាចណាស់! ខ្លាចចឹង ហើយម្យ៉ាងបងប្អូនរបស់ខ្ញុំ មានកំណើតកើតជាមិនដែលបានចឹង ហើយចឹងក៏ខ្ញុំទ្រាំ។ ខ្ញុំ គ្មានអ្នកណាចុង មានអីចុងដូចជាគេនុងនោះទេ ម្លោះហើយខ្ញុំបានតាមទ្រាំចៅនុង មកដល់ពេលឥឡូវនេះវាបានដឹងហើយ សព្វថ្ងៃនេះវាបានដឹងប្រាប់វាថាកុំអោយវាបានដើរនោះវាអត់ដើរនោះទេ បានទៅតែត្រឹមផ្ទះបងប្អូនឯងនៅជិតៗនេះចឹងណា។

ក៖ ហឹម!

ខ៖ ហើយបើសិនជា កូនគេខ្ញុំបានឃើញ។

ក៖ ហើយចៅនុងអោយគាត់បានចូលរៀនឬក៏បានតែនៅតែផ្ទះនោះទេ?

ខ៖ មិនទៅរៀនអីនឹងកើតបើសិនជាវាអត់មានបានចេះនិយាយហាំ វាបាននិយាយដែរ តែថាវាមិនបានច្បាស់ ទោះបើសិនជាបានរៀន អក្សរនោះក៏មិនចេះដែរ។

ក៖ ចុះមានបានអោយទៅពេទ្យគេពិនិត្យមើលអត់លោកយាយ?

ខ៖ ពិនិត្យមើលហើយ គេថាកំណើតកើតជាមកចឹងតែម្តង គ្មានស្អីនោះទេ គឺកំណើតកើតជានោះគឺវាចឹង។

ក៖ ចឹងសំរាប់ជីវិតរបស់លោកយាយវិញដែលបានឆ្លងកាត់ ជំនាន់មួយៗ ដែលជាជំនាន់មួយទៀត គឺជំនាន់ប៉ុលពត ត្រូវទេយាយ ហើយចឹងកាលនៅក្នុងជំនាននុងដូចជាយាយអឺ...គេបានប្រើយាយអោយបានធ្វើអីខ្លះដែរ កាលនៅជំនាន់ប៉ុលពត?

ខ៖ កាលនៅជំនាន់នុងបាន កាលពីមុនដំបូងគេបាន អោយខ្ញុំជាន់អង្គ ហើយនិងជាន់គ្បៀងណាស់ បានជាន់ស្រូវ កិនស្រូវនឹងត្បាល់នុងយកអ៊ុំយកអង្កាចេញចឹងទៅ ដើម្បីយកអង្គមកជាន់គ្បៀង វែងអោយគេចឹងទៅ កាលពីមុនដំបូងនោះគឺថាគេបានអោយយើងធ្វើចឹងទៅណា ដល់ពេលដល់ក្រោយមកទៀត គេបានប្រើអោយខ្ញុំបានត្បាញ់ ខ្ញុំធ្វើជាប្រធានខាងត្បាញ់ ខ្ញុំបានចេះត្បាញ់ តាំងពីដើមមក ខ្ញុំបានត្បាញ់ នៅខាងក្រោមផ្ទះហ្នឹងនៅតាមហ្នឹងណា។

ក៖ ហឹម!

ខ៖ ប៉ុន្តែវាវេទនាណាស់ចៅអើយ! យ៉ាប់ណាស់!ហ្នឹងហើយ។

ក៖ ចាំ! អូយាយអើយ!ហើយចឹងគេមានធ្លាប់ធ្វើបាបដល់យាយអត់ចឹង?

ខ៖ គេមានបានទៅធ្វើបាបអីនោះទេ តែគ្រាន់តែគេបានធ្វើបាបចឹងណា គេមិនមានបានទៅធ្វើបាបអីនោះទេ ទៅជេរស្តីអីអោយដល់ខ្ញុំ ដូចថាក្មេងៗគេបានធ្វើអោយបានមុខព្រួញ។

ក៖ ហឹម!

ខ៖ ចាំ!

ក៖ ហើយទៅយាយដូចជាបានធ្លាប់ឃើញប៉ុលពតយកមនុស្សទៅសម្លាប់ចោលនៅនឹងភ្នែករបស់លោកយាយដែរឬទេនៅកាលនុង?

ខ៖ មិនដែលបានធ្លាប់ឃើញនោះទេ ! បាន៣នាក់ទៀត កាលនុងមានប្រុស១នាក់ ហើយនិងស្រីបាន១នាក់ គេបានអោយទៅធ្វើការ ចាប់នៅឯនុងចឹងតែម្តងនោះទេណា គេបានអោយយកទៅហើយខ្ញុំបានទៅមើល តែអត់មានបានឃើញកូននោះទេណា ប៉ុន្តែគ្រាន់តែបានឃើញថាគេបានយកពីផ្ទះទៅ។ចាំ!

ក៖ ហឹម!

ខ៖ ខ្ញុំអាណិតកូន ខ្ញុំបានអោយកូនស្លៀកពាក់ខោអាវល្អទៅ!ណា! អាណិតកូនបើសិនជាបានងាប់ឬក៏ជា តែថាអោយបានខោអាវល្អបានស្លៀកខ្ញុំបានថាចឹងណា។ អា! ដល់ពេលបានបណ្តើរទៅ ចឹងអត់មានបានហ៊ានយំអោយគេបានឃើញនោះទេចៅ។

ក៖ហឹម!

ខ៖ ព្រោះអីបើសិនជាយំអោយគេឃើញ ខ្លាចគេបានយកយើងទៅទៀត។

ក៖ ហឹម

ខ៖ ខ្ញុំហ្នឹង! ចេះតែថាអត់ អើយអត់! ចឹងខ្ញុំបានចេះតែរស់ទៅអាយុបានវែងនោះ កូនបានងាប់ចោលទៅអស់រលីង ចេះតែនៅទៅ ហើយចេះតែរស់ទៅ នៅដល់ទៅ៩១ទៅ កាលគេបានចាប់កូនរបស់ខ្ញុំ ខ្ញុំមានអាយុទើបតែ៦១នោះទេណា។

ក៖ ហឹមយាយអើយ! ហើយពេលជំនាន់នុងផងដែលយាយកូនរបស់ខ្ញុំដូចថាអឺ...គេបានធ្វើយ៉ាងម៉េចខ្លះដែរ បានជាយាយស្តាយកូននៅពេលនុង?

ខ៖ ឯណា?

កះ កូនរបស់យាយដែលបានស្លាប់នៅក្នុងជំនាន់ប៉ុលពតនុងណា។

ខះស្តាយ! តែមិនដឹងថាត្រូវធ្វើយ៉ាងម៉េចបើសិនជាគេបានយក កូនទៅបាត់ទៅហើយ មិនបានដឹងថាគេយកទៅដំណា យើងវាអត់មានបានដឹងនោះទេ។

កះ យាយអត់មានបានដឹងថាកូនរបស់យាយបានធ្វើអីគេខុសអី?

ខះ មិនបានដឹងជាខុសអីនោះផង។

កះ ចឹងគេចេះតែយកទៅ?

ខះចាំ!

កះ គ្រាន់តែធ្វើការនុង គឺបានដឹងថាអាប្រុសាបាន១នាក់ ហើយអានុងគឺគេបានធ្វើខាងយោធា។ វាអឺ!...ប្រធាន កងធំ ហើយគេបានដាក់អោយធ្វើយោធាទៅ ចឹងគេបានដាក់អោយធ្វើយោធានុងគឺជាយោធាប្រធានកងធំហើយណា។ ចាំ! ធ្វើមានកងការពារអីមកទៀត មានអី ចឹងដែលកូនរបស់ខ្ញុំអាមួយដែលគេបានយកទៅនុងណា! ដល់ពេលផុតពីនុងមកគឺថាអានុងវាមិនល្អនោះទេ ដល់ពេលអត់ល្អចឹងក៏ចោលទៅ អា! យកចេញទៅ គេបានយកអាណាទៅធ្វើទៀត គេបានយកកូនរបស់ខ្ញុំទៅ! ហឹម ខ្ញុំដឹងបានតែប៉ុណ្ណឹងខ្ញុំមិនបានដឹងថាកូនរបស់ខ្ញុំវាបានធ្វើអីគេខុសអីនោះទេ។

កះ ហឹមចាំ! ហើយទៅនៅក្នុងសម័យនុងផងដែរ តើលោកយាយមានបានចង់ចាំទិដ្ឋភាពអីគេជាងគេតែម្តងដែលធ្វើអោយលោកយាយបំភ្លេចមិនបានសោះ?

ខះ ចាំអីគេចៅ?

កះ ចាំដូចថាគេមានបានធ្លាប់ធ្វើបាបយាយ ឬក៏គេបានធ្លាប់ ប្រើយាយអី ដែលបានធ្វើអោយយាយចង់ចាំអត់មានបានភ្លេចសោះតែម្តងណា កាលនៅក្នុងជំនាន់ប៉ុលពតនុង?

ខះ គេប្រើតើ! គេប្រើខ្ញុំហ្នឹងដំបូងធ្វើអង្គ ដល់ពេលបានធ្វើអង្គ ហើយក៏គេបានអោយមកត្បាញ់ចាំ! ហើយដល់ពេលត្បាញ់ហើយទៅដល់ទៅពេលដែលបានចប់នុងណា។ បានពេលដាច់នុងណាបានជាបាននុងណាមិនបានទៅធ្វើអីគេទៀតនោះទេ ខ្ញុំហាំ ។

កះ ហឹម!

ខ៖ ខ្ញុំមានបានទៅស្ទូងដកមានបានទៅអីនោះទៀតនោះទេ គ្រាន់តែថាខ្ញុំនៅឯខាងផ្ទះរបស់ខ្ញុំនុង ចឹងដល់ថាខ្ញុំបានរាងបានចំណាស់ណាស់ទៅហើយបានជាខ្ញុំចេះត្បាញ់ កាលពីមុនមកណាខ្ញុំបានធ្លាប់ធ្វើត្បាញ់ រាល់ឆ្នាំចឹងទៅ កាលនុងគឺខ្ញុំបាននៅកើតទាន់អាពតនោះ។

ក៖ ចាំលោកយាយ! ហើយទៅលោកយាយកាលនៅក្នុងជំនាន់ប៉ុលពតនុងផងដែរ តើលោកយាយមានដែលឈឺអីអត់លោកយាយ?

ខ៖ ឈឺក៏មិនដែរជាឈឺ មិនដែលឈឺអីអោយគេបានលំបាកនឹងខ្ញុំនោះទេ។ហឹមអត់មានអីនោះទេ! បានឈឺដែរ បានតែបន្តិចបន្តួចចឹងទៅ គេបានអោយថ្នាំលេបអីចឹងទៅ ហើយក៏បានបាត់ទៅ មិនដែលបានឈឺដេក ដួលនៅលើគេបានយូរអីនោះទេ ទាល់តែមកដល់សព្វថ្ងៃណាថៅ។

ក៖ អូ!...

ខ៖ ចាំ!

ក៖ចឹងសុខភាពរបស់លោកយាយបានល្អណេស?

ខ៖ សព្វថ្ងៃនេះក៏មិនដែលបានឈឺអីដែរ បើសិនជាឈឺដៃឈឺជើងអីនោះគឺបានឈឺមែនណាខ្ញុំបើសិនជាខ្ញុំគឺថាបានដើរទៅឈឺដៃជើង ចឹងបានថាកូនគេបានធ្វើអោយហូបនៅពេលស្នាណានោះក៏បានហូបនៅស្នាហ្នឹងទៅ មិនដែលបានទៅខឹងកូន ហើយជេរកូនរបស់ខ្ញុំនោះទេ។

ក៖ ហឹម! យាយនៅពេលទំនេរៗដូចចិត្តធ្វើអីគេដែរ?

ខ៖ ខ្ញុំហាំ នៅពេលទំនេរៗចឹងធ្វើអីកើតដែរ ដូចថានៅពេលកូនគេបានអុសមកចឹង ហើយបានអង្គុយកាប់អីចឹងដែរ នោះអុសហាំ (លោកយាយបានចង្អុលបង្ហាញកន្លែងដែលកាប់អុសហើយដាក់គទុក)។

ក៖ ហឺ! លោកយាយអង្គុយកាប់អុស?

ខ៖ ហ្នឹងហើយបានអង្គុយកាប់បានអុស ខ្លីៗចឹងទៅ ហើយបានគ យកមកដាក់នៅក្បែរចង្កានមកបើសិនជា គងមិនរួចនោះទេ គឺថាអោយកូនគេបានគង មក។

ក៖ ចាំ!

ខ៖ បានចឹងដែរថៅណា មិនមែននៅស្ងាមទទេរនោះទេ!។

ក៖ហ្នឹងហើយបានហាត់ប្រាណយាយនេស?

ខ៖ ហ្នឹងហើយតែថាបើសិនជាបាយអីនោះ គឺថាកូនគេបានអោយយាយដាំទៀតនោះទេ ព្រោះអីខ្លាចរលាក!។

ក៖ ហឹម!

ខ៖ ព្រោះអីខ្ញុំធ្លាប់បានដើរទាត់! កាលនុងពេលដែលបានដាំបាយរួចស្រាប់តែបានដើរទៅទាត់ មិនដឹងថាបានដើរទៅទាក់នឹងស្អីនោះទេ ក៏បានដើរទៅកន្លែងឆ្នាំនុង ហើយបានដើរទៅទាត់នៅកន្លែងឆ្នាំនុងបាន១ដង ។

ក៖ ហឹម

ខ៖ហើយដល់ពេលតាំងពីនុងមកគឺថាវាលែងអោយខ្ញុំដាំចឹងទៅ។

ក៖ ហឹម!

ខ៖ ហើយអារឿងនុងតាំងពីពេលនៅឆ្នាំ៩០មែសដែលបានរលាកនុងណា។

ក៖ចាំ!

ខ៖ ហើយមកដល់ពេលឥឡូវនេះបានចូលឆ្នាំ៩១ហើយ។

ក៖ ចាំហើយចឹងយាយសំរាប់មុខម្ហូបវិញ តើយាយចូលចិត្តពិសារមុខម្ហូបអ្វីដែរ?

ខ៖ ម្ហូបហ៎ តើម្ហូបអីគេចៅ?មុខម្ហូបសំរាប់យកមកហូបបាយហ្នឹងហេស?

ក៖ ចាំ!

ខ៖ ខ្ញុំហ៎ ហូបមុខម្ហូបអីគេក៏បានដែរ!បានមកក៏ហូបទៅ បើសិនជា កូនវាក្រចឹងបានអីមកអោយដល់ម្តាយ? ហើយចឹងមកដល់ពេលសព្វថ្ងៃនេះគឺថាខ្ញុំបានខ្លាច គឺថាបានខ្លាចនៅពេលរឿងចៅហ្នឹង ចៅរបស់ខ្ញុំវាមានបានរឿងណាស់ មានទៅដល់១៥ មានចៅៗបាន១៣សំបុកហើយនោះ ។ចាំខ្ញុំបានចៅៗនុងទៅ កាលពីមុនគេបានទិញអីយកមកអោយហូបចឹងទៅ ដូចជានៅពេលចូលឆ្នាំអីគេបានយកលុយមកអោយមានម្នាក់បាន១៥០០អីគេបានចេះតែយកអោយមកក៏បានហូបទៅ បានទិញអីហូបទៅ នៅខែភ្ជុំចឹងគឺថាគេបានយកអីមកអោយ គេបានអោយអីយកមកហូបចឹងទៅ បើសិនជាគ្នាបានបន្តិចចឹង តើទៅរកអីគេបានមកច្រើន?

ក៖ ចាំ!ហឹមយាយអើយ!

ខ៖ មិនមែនដូចជាយើងទៅរកអីកាលពីដើមនោះទេណាចៅ ។

កៈ ចាំ

ខៈ វេទនាណាស់ជំនាន់របស់ខ្ញុំ។

កៈ ម្ហូប ដូចថាចូលចិត្តម្ហូប គឺម្ហូបខ្មែររបស់យើងណា?

ខៈ ម្ហូបខ្មែរយើងហ្នឹង១ណាក៏មិនឆ្ងាញ់ដែរ ១ណាក៏ស៊ីមិនកើតដែរ។

កៈ ចាំ!ចឹងមានត្រី សាច់ មានអីចឹងទៅ!

ខៈ មានខ្លះគេបានស្លគកូរទៅ ខ្លះក៏បានស្លប្រហើរចឹងទៅ ចេះតែហូបទៅកើតហើយ តើទៅរើសអីពីណាមក បើសិនជាយើងធ្វើអីមិនកើតហើយ។

កៈ ហ្នឹងហើយ!

ខៈ អឺ ចឹងមានប៉ុន្មានក៏ហូបប៉ុណ្ណឹងទៅ។

កៈ ហើយចុះបន្លែអីយាយបានដាំដោយខ្លួនឯងឬក៏បានទិញគេពិសារដែរ?

ខៈ ចំពោះបន្លែអីបានទិញគេពីផ្សារថៅ។

កៈ ហឹម!

ខៈ តែដល់ពេលខែមានទឹកភ្លៀងមកគឺបានដាក់ដាំបន្លែដូចមាន ត្រលោច ននោង ដូចជាមានសណ្តែក មានដូចជាអីចឹងទៅ ចឹងមានននោងមានអីចឹងទៅ បានបេះស្លនុងចឹងទៅ ដូចជាខែប្រាំងដាំមិនបាននោះទេ ព្រោះអីដងស្រោចទឹកវាមិនរួច។

កៈ ចាំ!ហើយសំរាប់ដល់ពេល មុនហ្នឹងទៀត ដូចជាត្រីអីតើយាយបានទិញគេឬក៏បានទិញគេយកមកធ្វើដែរយាយ?

ខៈ អូយ! គ្មានពីណាទៅរក បើសិនជាសុំសីលអស់ទៅហើយ ចំពោះកូនរបស់ខ្ញុំនោះក៏ជាអ្នកសុំសីលដែរ ដូចថាបានទៅទិញគេធ្វើស្រាប់នោះទេ ដែលថាយកមកធ្វើម្ហូបហូបនុង។

កៈ ចាំ!

ខៈ សូម្បីតែថាត្រីរស់នោះគឺថាមិនដែរបានទិញគេហូបនោះដែរ ពងមាន់ ពងទារអី ដែលមាននោះគឺមិនដែលបានចិញ្ចឹមខ្លួនឯងដែរ ទិញគេហូប ទាំងម្តាយទាំអកូន ព្រោះអីរវល់ អាកូននោះគេបាននៅឆ្ងាយៗ ដល់ពេលគេបានយូរៗគេបានមកម្តង។

កៈ ហ៊ឹម!

ខៈ សូម្បីតែត្រីអីនុង បានទិញគេយកមកប្រឡាក់ទៅ បានស្មោរស្លឹកអំពិលអីបានហ៊ុចចឹងទៅ។

កៈចាំ

ខៈ វេទនាណាស់!

កៈហើយយាយអឺ...នៅម៉ាំងណាយាយ! យាយមានដែរទៅពេទ្យទេ?

ខៈ មិនដែរនោះទេ!

កៈ អត់ដែរទៀត!

ខៈ បើសិនជាខ្យល់ចាប់អីចឹង វិលមុខអីចឹង ហៅពេទ្យមកហើយ អោយគេបានមក ចាក់ហើយបានតែ៣ទៅ ៤ម្ទុលអីចឹងក៏បានស្វាងចឹងទៅ ដល់ពេលផ្កាសាយចឹងទៅគឺថាហៅពេទ្យគេចឹងមកទៅ ពេទ្យដែលគេនៅនឹងស្រុកនេះចឹងណា ហើយក៏បានហៅគេមក ហើយគេក៏បានមកចាក់អោយចឹងទៅ នៅក្នុងឆ្នាំនេះគឺថាគេបានមកចាក់អោយបាន២ដងហើយ ប៉ុន្តែវាមិនអីនោះទេ ចាក់ទៅជា ចាក់ទៅបាត់ វាអត់អី។ ខ្ញុំមិនដែរបានឈឺដេកដួលនោះទេ!

កៈហ៊ឹម!

ខៈ ចាំ!

កៈ ចាំ

ខៈ វាបានចឹង!

កៈ ចាំ!ហើយទៅដូចជាថ្នាំខ្មែរអីតើលោកយាយបានដាំផឹកដែរស?

ខៈ ថ្នាំខ្មែរ មិនដែលបាននោះទេ យើងបានលេបតែថ្នាំ ចុក ព្រោះអីដូចថាដូចជារោគរបស់យើងវាមិនត្រូវនឹងថ្នាំខ្មែរ។

កៈ ហ៊ឹម!

ខៈ ចាំ!

ក៖ ចាំ! ហើយយាយខ្លួនឯងតែម្តង តើលោកយាយមានបានចូលចិត្តស្តាប់ ដូចជាបទចម្រៀងអីដែរឬទេកាលពីនៅក្មេងណា?

ខ៖ នៅឯណា?

ក៖ នៅកាលពីសម័យមុនណា តើលោកយាយមានបានចូលចិត្តស្តាប់បទចម្រៀងឬក៏រាំអីដែល?

ខ៖ ហឹម! ខ្ញុំមិនបានចេះនោះទេ!

ក៖ ហេសៗ

ខ៖ ចាំមិនបានចេះនោះទេ! កាលពីដើមមកការខ្ញុំគឺគេបានរាំ អត់មានបាស គ្មានបាំងអីនោះទេ គេរាំស្គរដៃនុង រាំដៃរគេអ្នកមកការនុងណា គេបានរាំគេបានរែកអីចឹង ខ្ញុំមិនបានដឹងថារាំអីយ៉ាងម៉េចនោះផង គឺខ្ញុំមិនបានចេះរាំរែកអីនោះទេ! ខ្មាសគេ។

ក៖ ចាំខ្មាសគេណ៎ យាយនេស?

ខ៖ ចាំ!

ក៖ តែយាយដូចជាចេះច្រៀងដែរឬទេយាយ?

ខ៖ អូ! មិនចេះនោះទេខ្ញុំ អីក៏វាមិនចេះដែរ! ច្រៀងក៏ខ្ញុំមិនចេះ ហើយអក្សរក៏ខ្ញុំមិនចេះ នេះប្រាប់ត្រង់ចឹងហើយ។

ក៖ ចាំ!

ខ៖ខ្ញុំមិនបានរៀនអីនឹងគេនោះទេ។

ក៖ ចាំ! ហើយដល់ពេលជំនាញខាងធ្វើសិប្បកម្ម ដេរ ត្បាញអីតើយាយចេះតែឬទេ?

ខ៖ ខ្ញុំចេះ ត្បាញក្រមា ត្បាញអីនុង ខ្ញុំបានចេះតាំងពីពេលត្បាញកន្ទេលក្រមាឡើង ដែលបានកាត់យកពីបឹងមក យកមកហាលអោយវាបានស្ងួតទៅ យកវាមកច្រលក់ល័ក្ខ ច្រលក់ពណ៌ចឹងទៅ ត្បាញកន្ទេលក្រមាខ្ញុំចេះណា ហ្នឹងណា! ត្បាញ ខ្ញុំបានធ្វើការក្រមាយើងខ្ញុំចេះត្បាញ ខ្ញុំបានផ្តាំទៅក្រុមការងារហើយ ថាចេសៗ ខ្ញុំបានដឹងទាំងអស់ ហើយដល់ពេលមកដល់អាពតនេះហ្នឹងគឺខ្ញុំបានធ្វើចឹងដែរ ព្រោះអីគេបានដឹងថាខ្ញុំចេះ ។

ក៖ ហឹម!

ខ៖ ចាំខ្ញុំបានឈប់ធ្វើអីអស់ហើយ ខ្ញុំបានមកនៅត្បាញ់ធ្វើអីដែរ តែដល់ពេលបានដាច់នុងខ្ញុំបានឈប់តែម្តង។

ក៖ ចាំ!

ខ៖ ចាំ!

ក៖ ហើយយាយមានបានប្រើឧបករណ៏អ្វីត្បាញ់ដែរ កីអី?

ខ៖ កីគេធ្វើអោយ!

ក៖ ចាំ!

ខ៖ មានជាងគេ មានគ្រូសិប្បកម្ម ខាងកីអីនុង បើសិនជាថាខ្វះកីនុង តែ២ថ្ងៃទេ គេអាចធ្វើយកមកដាក់វិញបាន។

ក៖ ចាំ!

ខ៖ ហើយបើសិនជាយើងបានធ្វើតែ២ថ្ងៃអីនុង គេអាចយកមកអោយយើងបានត្បាញ់ហើយ។

ក៖ចាំត្រូវហើយ!

ខ៖ ហើយដូចជាកន្ទេលអីនោះគឺថាខ្ញុំចេះធ្វើដែរ ហើយគឺថាខ្ញុំធ្វើបាន ។

ក៖ ហើយចឹងកន្ទេលនេះអីយាយបានធ្វើដោយសារតែស្នាដៃរបស់យាយ?

ខ៖ ចាំ!

ក៖ហើយអឺ! បានចេះអំពីជីដូនជីតាឬក៏បានចេះពីណាមក?

ខ៖ រៀនពីដូនពីតារបសខ្ញុំមកបានធ្វើចឹងតែម្តង។

ក៖ ហឹម!

ខ៖ បានធ្វើតែកន្ទេលត្នោតនុងប្រើ ហើយខ្ញុំចេះធ្វើតែកន្ទេល ខ្ញុំបានចេះធ្វើស្មុក ចេះធ្វើតាំងពីស្មុកកាប៉េត និងស្មុកមូល ។

ក៖ ចាំ!

ខ៖ អើ!

កៈ ហើយទៅយាយធ្វើដើម្បីនឹងប្រើប្រាស់នៅក្នុងផ្ទះរបស់ខ្លួនឯងឬក៏...

ខៈ ធ្វើគ្រាន់តែបានប្រើដោយខ្លួនឯង។

កៈចឹងយាយអត់មានបានធ្វើលក់នោះទេហ៎?

ខៈ អត់មាននោះទេ! ធ្វើគ្រាន់តែបានប្រើដោយខ្លួនឯង ចឹងគេទិញធ្វើអីមានគេចេះដៃរនុង។

កៈ ចា៎!

ខៈ ចៅអើយចៅ! ខ្ញុំនើយណាស់! ខ្ញុំបានរកដែលមិនថាមិនបានរកសោះនោះទេ! ណាមួយនៅកំលាំងធ្វើកើតនោះខ្ញុំនៅមានកំលាំងដេរស្លឹកលក់ បានចាយអីខ្លះដោយសារតែចឹងទេ ហើយមានបានដឹកគោ បានដឹកក្របីអីខ្លះចឹងទៅ ហ៊ឹម ។

កៈ ចា៎!

ខៈ មានបានដឹងថារកស៊ីអីនោះទេចៅអើយ!

កៈ ចឹងយាយបានឧស្សាហ៍ព្យាយាមកាលពីនៅក្នុងសម័យមុនណា យាយចឹងកាលពីសម័យមុននឹងផងដែលបងប្អូនរបស់យាយនឹងយាយណាមានអនុស្សាវរីយ៍អីគេខ្លះជាមួយនឹងគ្នាយាយ?

ខៈ ឯណា?

កៈ បងប្អូន!របស់យាយណាតើយាយមានបងប្អូនដែរឬទេ?

ខៈ ខ្ញុំមានបងប្អូន មាន២នាក់!

កៈ បងប្អូន២នាក់ចឹងតើគាត់មានឈ្មោះអ្វីគេខ្លះដែរយាយ?

ខៈ ក៏ប៉ុន្តែបានងាប់អស់ហើយ! បងមួយគេបំផុតមានឈ្មោះថា ចៅអែង!។

កៈ ហ៊ឹម!

ខៈ ចា៎បងប្រុសរបស់ខ្ញុំមានឈ្មោះថា លោកបងគុង!

កៈហ៊ឹម

ខៈ ចា៎បងប្អូនរបស់ខ្ញុំមានតែ៣នាក់នុងនោះទេ។

កៈ ចាំចឹងយាយជាកូនទី៣ពៅគេហេសយាយ?

ខៈ ចាំម្ដាយរបស់ខ្ញុំមានកូនតែ៣នាក់នុងទេ។

កៈ ចាំ!

ខៈ ប៉ុន្ដែគាត់ងាប់អស់ហើយ បាននៅតែខ្ញុំនេះបានតែ១នាក់នោះទេ។

កៈ ហឹម!

ខៈ ខ្ញុំពៅគេ! ហើយទៅនៅរស់បានយូរណាថៅ។

កៈ ចាំ! ហើយទៅយាយមានអនុស្សាវរីយ៍អ្វីបានធ្លាប់លេងអីជាមួយនឹងពួកគាត់ដែរឬទេ កាលនៅពីក្មេងៗ កាលនៅពីកុមារភាពណា?

ខៈ ទេ! ខ្ញុំមិនដែរនោះទេ! មិនដែលបានលេងអីជាមួយនោះទេ ខ្ញុំមិនបានចេះអីចឹងតែម្ដង គឺថាមនុស្សខ្ញុំនេះគឺថាបើសិនជាទៅស្ទូងនោះគឺថាទៅស្ទូងហើយ តែបើសិនជាថាបានទៅនៅឯផ្ទះនោះគឺនៅឯផ្ទះហើយ ហ្នឹងតែប៉ុណ្ណឹង។

កៈ ហឹម!

ខៈ ចាំ!

កៈ ចាំហើយចឹងលោកយាយកាលពេលនៅក្នុងសម័យកាលពីនៅក្នុងកុមារភាពនុង តើលោកយាយមានមិត្តភក្ដិដែរឬទេ? គឺដូចជាមានមិត្តភក្ដិស្និតស្នាលណា?

ខៈ អត់នោះទេ ខ្ញុំគ្មានបានមានមិត្តអីនោះទេ! មានតែស្រីៗគ្នាៗឯងនុង ដែលបានធ្វើការងារនៅជាមួយនឹងគ្នា មានការស្ទូងដកអីមានតែអ្នកទាំងអស់ហ្នឹង មានតែស្រីៗហ្នឹង មានតែក្រុមុំៗដូចៗគ្នានុង។

កៈ ហឹម!

ខៈ បើសិនជាមួយនឹងមិត្តភក្ដិប្រុសខ្ញុំមិនដែរបានទៅស្គាល់គេនោះផង ខ្ញុំមិនដែលបានទៅហ៊ានស្ដីរកគេនោះផង!កាលនោះខ្ញុំ។ បើសិនជាអ្នកណាដែលមិនមានបងប្អូននោះខ្ញុំមិនស្ដីរកនោះទេ!ចាំ!

កៈ ហឹម មិនចឹងយាយ?

ខ៖ ដូចថាបើសិនជាបងប្អូនរបស់ខ្ញុំដូចជាត្រូវជាជីដូនមួយ ត្រូវនឹងជីទួតមួយអីនុងខ្ញុំបានស្តី! ហើយបើសិនជានៅក្រៅពីនុង នៅក្នុងស្រុកភូមិជាមួយខ្ញុំមិនដែលបានទៅមាត់ដាក់ពីណានោះទេ។

ក៖ ហ៊ឹម! អៀន ឬក៏អត់ចង់ស្តីរកគេ?

ខ៖ អៀនតែម្តង! ដូចតែមិនហ៊ានបានស្តីរកគេ។

ក៖ ចាំ!

ខ៖ ចឹងតែម្តងណាខ្ញុំ។

ក៖ ហ៊ឹម!លោកយាយចឹងនៅពេលកាលដែលការនុង តើលោកយាយគាត់មានអាយុបានប៉ុន្មានដែរលោកយាយ កាលដែលគាត់បានរៀបអាពាហ៍ពិពាហ៍ណា?

ខ៖ កាលពេលដែលរៀបខ្ញុំ គាត់បានបងខ្ញុំបាន៣ឆ្នាំ។ខ្ញុំកាលនុងបាន២២ ហើយគាត់កាលនុងបាន២៤! ចឹងហោស? ២៤ហោស?

ក៖ អឺ....បងបាន៣ឆ្នាំហោសយាយ?

ខ៖ អឺ!បង៣ត្រូវ២៣ហោស?

ក៖ ២៥!

ខ៖ ២៥ហ៎?

ក៖ ចាំ!

ខ៖ ចឹងហ្នឹង!គាត់បានបងខ្ញុំ។

ក៖ចាំចឹងនៅពេលនុងតើគាត់បានប្រកបមុខរបរអ្វីដែរចឹងនៅពេលនុង?

ខ៖ គាត់បានធ្វើតែស្រែ ជួបគាត់នៅពេលណាគាត់អត់មានបានទៅធ្វើអីនោះទេ តាខ្ញុំព្រោះអីពេលនុងគាត់បានបួសលោក។

ក៖ ហើយបានបន្ទាប់មក?

ខ៖ ដល់ពេលបានបន្ទាប់មក បានជា គាត់បានមកដណ្ដឹងដល់ខ្ញុំហ្នឹង គាត់បានបួសជានេន ហើយ គឺគាត់បានបួសបាន៤ទៅ៥ព្រះវស្សានោះ ក៏គាត់បានសឹក ហើយក៏បានមកដណ្ដឹងខ្ញុំហ្នឹង។

ក៖ ចាំ!ចឹងហើយទៅលោកយាយគាត់គឺជាអ្នកនៅក្នុងស្រុកហ្នឹងដែរតើហេសយាយ?

ខ៖ ចាំ?

ក៖ លោកយាយកាលនុងលោកតានៅស្រុកហ្នឹងដែរ?

ខ៖ លោកតានៅស្រុកខាងអណ្ដូងដែងណោះ ។

ក៖ ចឹងលោកយាយអត់មានដែលបានស្គាល់គាត់ពីមុនមកនោះទេ?

ខ៖ ខ្ញុំមិនដែលបានស្គាល់នោះទេ ដល់ពេលដែលបានដល់ថ្ងៃរៀបការបានស្គាល់គ្នាតែម្ដង។ ចាំ! ក៏ប៉ុន្តែដល់ពេលចាស់!ៗនោះគាត់បានឃើញខ្ញុំ គាត់បានពេញចិត្តចឹងក៏គាត់បានអោយបានអោយមកស្ដីដណ្ដឹង។

ក៖ ហឺម!ចាំ! ហើយចឹងលោកយាយនោពេលនុងអត់មានដែលបានស្រលាញ់អត់មានដែលបានស្គាល់លោកតាកាលពីមុនមកសោះណាំ?

ខ៖ អត់ដែរនោះទេ!

ក៖ អូ!

ខ៖ ខ្ញុំអត់ដែរនោះទេ!

ក៖ ហើយដល់ពេលថ្ងៃការនុងតើយាយមានអារម្មណ៍យ៉ាងម៉េចដែរចឹង?

ខ៖ដល់ពេលនៅក្នុងថ្ងៃការនុងមានអារម្មណ៍ភ័យដែរនុង នៅតែភ័យ ហើយបាននៅតែខ្លាចគេ ប៉ុន្តែចាស់ៗកាលពីដើមគាត់ចេះ គាត់មុខនឹងការគាត់បានរក តាអំរបស់ខ្ញុំ នៅខាងស្រុកខ្វិតតូច បានមកស្រោចទឹក យកមកស្រោចអីអោយ បានស្រួលបួល ហើយបានការនុង ពេលនុងបានចេះតែខ្លាច ចេះតែញ័រ មនុស្សនៅសារនុងគឺថាបានខ្លាចណាស់ មនុស្សនៅសម័យស្រករខ្ញុំនុង។

ក៖ ហឹម

ខ៖ ហើយចុះមិនមែនបានការដូចជាក្មេងនៅសម័យឥឡូវហ្នឹងណាចៅ កាលនុងមានការបុកល័ក្ខ មានបង្វិលអង្គ ហើយបានអង្គុយ ដាក់អង្គរៀប មិនមែនដូចជានៅពេលឥឡូវនេះគេបានការតែ១ថ្ងៃៗឯណា។

ក៖ ហឹម

ខ៖ ខ្ញុំបានការ១យប់ ១ថ្ងៃ បានការនៅក្នុងថ្ងៃហ្នឹងបានកាត់សក់ ហើយដល់ពេលនៅក្នុងថ្ងៃហ្នឹងគឺថាបានធ្វើពិធីកាត់សក់ចឹងណា ហើយដល់ពេលនៅពេលល្ងាចបានធ្វើសែនចង់ដៃ ហើយដល់ពេលឥឡូវនេះគេបានគ្រេងគ្រេងអីនុងគឺវាបានរួចអស់ទៅហើយ តែថាមកដល់ពេលឥឡូវនេះមិនថាកូនគេនោះទេ កូនរបស់ខ្ញុំនោះក៏ចឹង ម៉ាជំនាន់ហ្នឹង ហើយមកដល់ពេលជំនាន់របស់ខ្ញុំនោះគឺថាពិបាកនិយាយណាស់។

ក៖ហឹម!ចា៎ ចឹងលោកយាយនៅក្នុងជីវិតរបស់លោកយាយមានបានជួបនឹងបទពិសោធន៏ជីវិតច្រើនមែនទែន ហើយក៏បានឆ្លងកាត់បានច្រើនជំនាន់ដែរ អញ្ចឹងមានរឿងអីដែលបានធ្វើអោយយាយសប្បាយចិត្តជាងគេមានអីគេដែរលោកយាយ?

ខ៖ ចា៎?

ក៖ រឿងដែលបានធ្វើអោយលោកយាយសប្បាយចិត្តជាងគេ មានអីគេដែលលោកយាយ?

ខ៖ សព្វថ្ងៃហ្នឹងហោស?

ក៖ ចា៎!

ខ៖ បើសិនជាសព្វថ្ងៃហ្នឹង បើសិនជាថាសប្បាយទៅនោះក៏វាមិនដឹងថាជាមានអីសប្បាយប៉ុន្មានព្រោះយើង ក្រ ហើយវាអត់មានជាប់ហើយចឹងវា អស់អីធ្វើ ខ្ញុំនេះវាគ្មានបានមានកូនអីគេធ្វើចឹង ខ្ញុំនេះដូចថាវាគ្មានដូចជាម៉ាស៊ីនកិនស្រូវ មានម៉ាស៊ីនប៊ូមទឹក មានម៉ាស៊ីនអីនោះគឺគ្មាននោះទេ។ គ្មានអ្នកណាមកកាន់គ្មានអ្នកណាបានប្រើនោះ បើសិនជាថាបើចង់ដាក់ទឹកនោះជួលគេបានមកដាក់ទៅ ម៉ាស៊ីននុងណាមាន។

ក៖ ហឹម

ខ៖ គេមានប្រុស ហើយដល់ពេលខ្ញុំមានកូនតែស្រី១ហ្នឹងនៅតែ១ហ្នឹងចឹងមានឯណា តើមានអ្នកណាគេបាននឹងកាន់ម៉ាស៊ីន ម៉ាអី!។

ក៖ហឹម

ខ៖ ចឹងបានថាពិបាកណាស់ចៅអើយ!

ក៖ ហើយចឹងសំរាប់រឿងដែលបានធ្វើអោយលំបាកចិត្តជាងគេវិញ តើមានរឿងអីគេខ្លះដែរ?

ខ៖ ខ្ញុំវេទនាណាស់ចៅ! ថាម៉េចចៅ?

ក៖ រឿងដែរធ្វើអោយលោកយាយបានលំបាកចិត្តជាងគេណា ដែលលោកយាយលំបាកចិត្ត មានរឿងគេខ្លះដែរ?

ខ៖ មានរឿងអីដែលមិនធ្វើអោយលំបាកចិត្ត បើសិនជាវាបានយ៉ាប់ទៅ បើសិនជាមានកូនតែ១ ឯង ហើយមានកូនបានចិញ្ចឹមអីផង ម្តាយនេះចាស់ធ្វើអីមិនកើតនោះគឺបានអាណិតកូន ចឹង នៅក្នុងពេល១យប់ៗខ្ញុំជួនណាដេក អត់មានបានលក់នោះទេចៅអើយ! នឹកអាណិតកូន រួច ដូចជាវាបានថាវាអស់កំលាំងដែរ ក៏ប៉ុន្តែយើងបានចេះទប់ អាវាមិនឈឺចឹងក៏បានចេះតែទប់ កម្លាំងចឹងទៅ។

ក៖ហឹម! ចឹងលោកយាយនៅពេលលំបាកចិត្តតែងតែធ្វើអ្វីដែរ?
ខ៖ បើសិនជាពិបាកចិត្តខ្លាំងមែនទែនទៅ អង្គុយនៅលើផ្ទះចឹងទៅ មើលនេះនោះ តែអត់មាន មនុស្សឯណា បើសិនជាមានតែ៣នាក់ មានតែ១មីកូន ហើយនិងមីចៅ ដែលថាមិនសូវគ្រាប់ ដឹង១នុង ចឹងមានតែ៣នាក់ហ្នឹងហើយថាអស់ពីនុង គឺថាបានមី១នាក់នោះបានគេទៅនៅឯ ភ្នំពេញចៅណា ហើយមី១ទៀតនុងគេបានមកនៅឯហ្នឹងហើយ ដោយសារតែគេមានកូនខ្ចីចឹង គេបានមកនៅផ្ទះ នៅខាងប្តីគេឯណោះ ហ្នឹងជាចៅ នៅខាងសំបុករបស់ខ្ញុំហ្នឹងហើយដល់ ពេលមាន១សំបុកទៀត គេបានទៅនៅឯខាងផ្ទះម្តាយឪគេចឹងទៅ ចឹងសំបុករបស់ខ្ញុំ មាន៣ ហ្នឹង។

ក៖ហឹម!

ខ៖ អឹម!

ក៖ចឹងលោកយាយជាចុងក្រោយលោកយាយមានចង់បានអីគេដែរនៅក្នុងជីវិតរបស់លោក យាយណា?

ខ៖ ចាំ?

ក៖ លោកយាយចង់បានអីគេដែរ តើមានបំណងប្រាថ្នាអីគេដែរសំរាប់ជីវិតរបស់លោកយាយ?

ខ៖ ខ្ញុំមិនបានដឹងថាមានការប្រាថ្នាអី មិនដឹងថាចង់បានអីពីគេនោះទេ តែថាបើសិនជាគេដឹង យាយចឹងគេបានយកអីមកអោយចឹងទៅ ហើយបើសិនជាគេមិនដឹងនោះទេ ក៏មិនហ៊ានបាន សុំទារគេនោះដែរចៅ។

ក៖ ហ៊ឹម

ខ៖ ចាំ! ចិត្តនេះគឺចឹង មិនហ៊ានថា ចៅអើយ! យាយចង់បាននេះ យាយចង់បាននោះ មិនបាន ហ៊ានថាចាំ! សព្វថ្ងៃនេះគឺចង់បានកន្លែងនៅ ចង់បានកន្លែងងាប់ ថាសុំដីគេ ចង់សុំអោយគេ បានចាក់ដីបាន៩ទៅ១០ឡានសំរាប់ជាកន្លែងងាប់ចឹងណា នៅកន្លែងដីរបស់យើងនុងណា ហើយខ្ញុំបានសុំទុកដីនៅកន្លែងមុខផ្ទះនុង សំរាប់បញ្ចុះដល់ខ្ញុំ គឺថាខ្ញុំនៅឯហ្នឹងនោះទេ ខ្ញុំអត់ មានបានទៅក្រៅនោះទេ។ ចាំ! តែអត់មានហ៊ានសុំគេនោះទេចាំមើលសន្សំលុយខ្លួនឯង ហើយនឹងកូនចៅរបស់ខ្ញុំបានចូលមកចឹងបានសន្សំៗចាក់ខ្លះទៅ។

ក៖ហ៊ឹម

ខ៖ចាំ! ខ្ញុំមិនហ៊ាននោះទេ!អាណិតចៅណាស់គ្នាសុតតែបានធ្វើការងារដោយលំបាក ហើយសុ តតែបានដេរអីទាំងអស់ មីមួយក៏ដេរ មីពីរ ក៏ដេរ ហើយមានមី១ទៀតបានគេនៅលក់ឥវ៉ាន់បាន នៅជាមួយនឹងមីម្ដាយធំនោះបាននៅលក់ឥវ៉ាន់ ក៏ប៉ុន្ដែគេបានមានប្ដីអស់ទៅហើយ បានកូន១ បានកូន១អស់ទៅហើយ។

ក៖ ចាំ! ចឹងលោកយាយមានចង់បានអីគេទៀតដែរ?

ខ៖ ខ្ញុំចង់បានម៉េចទៀតចៅ?

ក៖ មានប្រាថ្នាចង់បានអីគេទៀត?

ខ៖ ប្រាថ្នាហាំ

ក៖ ចាំ!

ខ៖ ប្រាថ្នាចង់បានតែកន្លែង ចង់ពេលងាប់ទៅនុងអោយមានកន្លែងនៅតែប៉ុណ្ណោះ! ហើយនុង ដូចថា ចង់បាននោះគឺចេះតែចង់បានហើយតែនេះ កុំចង់បានពីគេហេសចៅនេស? ចាំមិនទៅ មាត់អីនោះទេ ស្រាប់តែចៅមើលឃើញអីចឹងទៅវិញ ប្រាថ្នាប្រាប់ទៅអ្នកក្រៅក៏អ្នកក្រៅគេបាន អាណិតដែរ អ្នកក្រៅដ៏ទៃ អ្នកដែលគេមានបាយសំឡ គេមានស្អី គេមានចំណី គេបានមក បញ្ជូនខ្ញុំអោយបានហូប ចឹងដែរខ្ញុំ។

កៈ ហ៊ឹម

ខៈ គេជាអ្នកក្រៅដ៏ទៃសោះនុង គេបានធ្វើជាចុងភៅបុណ្យនេះ កាលពីម្សិលម្ងៃនេះគេបាន ចាក់សម្លមកជូនដល់ខ្ញុំ បានអោយហូប សម្លនុងខ្ញុំបានហូប៣ថ្ងៃបានអស់ គេបានយកមកជូន ដល់ខ្ញុំណា។

កៈចាំ!

ខៈ ចាំខ្ញុំមិនសូវបាននេះនោះទេ គឺថាចៅៗគេបានចេះតែអាណិតដែរ អ្នកឆ្ងាយអត់បានដឹងអ្នក ដែលបានស្គាល់ៗនុងណា ហើយចឹងគេបានយកមកជូន ចឹងខ្ញុំមិនដែលបានសូវអត់នោះទេ គេបានចេះយកមកអោយមក ចឹងនៅពេល១ថ្ងៃនោះស្រាប់តែចៅរបស់ខ្ញុំបានទៅនុស គេបាន មកបើកមុងអោយដល់ខាងឪពុករបស់គេដែលផ្ទះខាងឪពុករបស់គេនៅខាងកោះធំ បាន៥នាក់ ហើយដល់ពេលមកគេបានជូនលុយបានបន្តិចម្នាក់ៗចឹងទៅគឺថាបានអរណាស់ចៅដែលបាន ចៅអោយ ចឹងគឺថាបានអោយម៉ាក អោយផល ដល់ចៅ បានទុកធ្វើបុណ្យនុង បានដល់ពេល ចូលឆ្នាំនុង។

កៈ ហ៊ឹម! ចាំ!ដើម្បីទុកធ្វើបុណ្យណ៎លោកយាយណ៎?

ខៈ ចាំ! បានទុកកសាងទៅមុខទៀតកុំអោយខ្ញុំបានវេទនា ។

កៈ ចាំ! ហើយចឹងកាលពីមុនអីតើលោកយាយបានទៅវត្តដែរឬទេលោកយាយ?

ខៈ ចាំមកដល់ពេលឥឡូវនេះអីកាលពីដើមអីចឹមិនទៅ! ខ្ញុំកាលពីដើមអីបានទៅសុំសីលនៅឯ វត្តតើដូចថាមកដល់ពេលឥឡូវនេះទៅវាមិនបានរួចនោះទេ ចឹងបាននិមិន្តលោកមកដើម្បី សូត្រនៅឯផ្ទះ។

កៈ ចាំ!

ខៈ ចឹងបានធ្វើធម៌អីដឹងគេចឹងទៅ ជួនកាលបានដើរទៅលបៗទៅ តែមកដល់ពេលឥឡូវនេះ ដើរទៅមិនរួចនោះទេចៅ ហើយបានខានទៅវត្តបានឡើង៥ឆ្នាំហើយ។

កៈ ចាំលោកយាយកាន់សីលប៉ុន្មានដែរ?

ខៈខ្ញុំកាន់ បាននៅសីល៥នៅឡើយនោះទេ ព្រោះអីខ្ញុំមិនបានកាន់សីល៨នោះទេ មកដល់ ពេលឥឡូវ! ដូចថាខ្ញុំនៅកាលនុងគឺខ្ញុំបានកំលាំងតិច ចឹងខ្ញុំបានអត់មានបានល្ងាចអីអត់បាន

កើតណា ចឹងកាលនុងខ្ញុំបាននៅជំនាន់កាន់សីល៥នុងគឺថាបាននៅចាំរបស់ខ្ញុំណាស់ មិនបានលំបាកនោះទេ គឺថាបានគិតទៅតាមព្រះធម៌និងព្រះសង្ឃជួយខ្ញុំ។

ក៖ ហឹម

ខ៖ ចា!

ក៖ ហើយទៅលោកយាយផ្ទាល់ខ្លួនឯងផ្ទាល់តែម្តងណា ពេលដេលបានកាត់ព្រះពុទ្ធសាសនារបស់យើងតើមានបានជះឥទ្ធិពលអ្វីគេខ្លះអោយដល់លោកយាយដែរ?

ខ៖ មាននៅពេលដេលបានកាន់ព្រះពុទ្ធសាសនានុងគឺថាជួយ! ជួយខ្ញុំបានឃើញនឹងភ្នែកនុងគឺថាបានឃើញផ្ទាល់នឹងភ្នែករបស់ខ្ញុំបានដូចថាប្រឹងអត់ប្រឹងអីនុងគឺបានដែរ មានគេបានជួយជូននេះបានបន្តិច មាននោះគេបានជួយជូននោះបានបន្តិចបន្តួចអីចឹងបានផ្តល់អោយដែរតើចៅ! មិនមែនថាអត់អំពើនោះទេ។ចាំ! ចៅបង្កើតៗនុង ថ្ងៃស្អែកទៅអ្នកនេះ ដល់ពេលនៅក្នុងថ្ងៃខាងស្អែកទៅអ្នកនោះគឺបានម្នាក់ៗមានចំណីអីចឹង គេបានទិញយកមកអោយចឹងមកជូនកាលគេបានទិញផ្ញើនៅអ្នកលក់ ហើយប្រាប់គេថា អានេះអោយ! ដែលនេះជារបស់ដែលគេបានផ្ញើអោយមកដល់យាយឯង ។ ដល់ទៅពេលចឹងទៅខ្ញុំនេះអត់មានដែលបានអត់នោះទេ តែគ្រាន់តែថា មិនមានបានដូចជារបស់យើង ចឹងតែថាយើងនេះមិនដឹងជាត្រូវជាថាយ៉ាងម៉េច ចឹងហើយបានត្រូវតែទ្រាំចឹងទៅណាចៅ ខ្ញុំបានទ្រាំ។

ក៖ ចាំ

ខ៖ ចាំ!

ក៖ បើសិនជាតារបស់ខ្ញុំគាត់បាននៅនោះគឺស្រួល! តើស្រួលយ៉ាងម៉េច គឺស្រួលធ្វើការ! គាត់បានខុចតាំងពីពេលអាយុបាន៦៦ គាត់បានខូចនោះណា គឺគាត់បានខូចនៅអាយុបាន៦៦ ហើយដល់ពេលខ្ញុំបាននៅដល់ទៅ៩១។

ក៖ ហឹម

ខ៖ ចឹងគឺថាខ្ញុំបានប្អូនទាំងគាត់ផង។

ក៖ ចាំចឹងនៅពេលកាលនុង យ៉ាងម៉េចបានជាគាត់ខូចចឹង?

ខ៖ ចាំ!

ក៖ គាត់យ៉ាងម៉េចបានខូចចឹងប្តីរបស់លោកយាយ?

ខ៖ គាត់ឈឺ! គាត់នុងគឺគាត់បានរាងធីធោង១ ឈឺដៃ ឈឺជើងចឹង ទទួល កូនរបស់ខ្ញុំនុង វាបានច្រូត វាបានច្រូត ហើយបានប្រាំង បានធ្វើប្រាំង ធ្វើស្រែអីគេរួចបានទៅច្រូតនៅប្រាំង ដល់ពេលច្រូតប្រាំងនុង មានបានបែននៅឯនុង ដល់ពេលបែននុងបានរាល់តែថ្ងៃចឹងទៅ វាបាននៅតែអាឡេង អាឡូ រួចអាកូនប្រសារនុងវាបាននៅឯនុងចឹង ហើយថាបានមកចោលស្រូវនេះបានមានស្រូវនៅច្រើននៅបាន២ដឹកនុងឯនុងចឹងណា ចឹងក៏បានយកស្រូវនុងបានមកសំងួតបើសិនជាដាក់បាវនុងមិនបានអស់នោះទេ គឺថាបានដាក់រទេះនោះបានជួយយកមកសំងួតទៅដល់នុង គាត់បានទៅគ្រុននៅឯនុងណា គាត់បានទៅគ្រុននៅឯព្រៃនៅឯនុង។

ក៖ ហឹម

ខ៖ គ្រុនទៅស្រាប់តែដល់ពេលព្រឹកព្រលឹមឡើងគាត់...អាកូនប្រសារនោះបានមកប្រាប់ថាម៉ែ១ គាត់បានរងារគាត់រួចខ្ញុំបានចូលមកចំបើង ដល់ពេលចឹងគាត់បានចូលមកនៅនឹងខ្ញុំយកទៅគ្រូមើល ដល់ពេលនុងគាត់បានវង្វេងតាំងពីពេលនុងមក បានជាមើលគាត់មិនជាដែរ ដូចជាមើលមិនជា ដូចជាមើលមិនបានត្រូវ។

ក៖ ហឹមចា៎!

ខ៖ ចា៎!

ក៖ សូមសរសើរដល់លោកយាយដែលបានចង់ចាំច្រើនណាលោកយាយ ហើយចឹងតើលោកយាយជាចុងក្រោយមានពាក្យពេចន៍អ្វីដើម្បីផ្ដែផ្ដាំដល់កូនចៅជំនាន់ក្រោយ ដែលគេបានស្ដាប់សំលេងរបស់លោកយាយផ្ទាល់ណា?

ខ៖ សូមផ្ដែផ្ដាំ ខ្ញុំសូមប្រាប់ដល់កូនចៅជំនាន់ក្រោយអោយវាបានធ្វើដូចជាខ្ញុំពីមុនចឹង កុំអោយចោលអាជំរិះ ខ្ញុំចឹង អាងថាស្អីក៏មានម៉ាស៊ីនអីក៏មានចឹងយើងត្រូវគិតក្រៅពីហ្នឹងវិញ។ មកដល់ពេលឥឡូវនេះតាំងពីអាម៉ូទ័រដែលគេបានដាក់ អណ្ដូងគេបានយកមកដាក់នៅខាងលើផ្ទះទៀត តែថាខ្ញុំនេះវាគ្មានចឹងក៏ខ្ញុំបានអីមកដាក់?

ក៖ហឹម

ខ៖ ដល់ទៅចឹងបានកូននោះវាបានចេះតែដងមកដាក់អោយមក។

ក៖ ហឹម!

ខ៖ ចា៎!អណ្ដូងរបស់ខ្ញុំមាន ប៉ុន្ដែវាអត់មានអីប៊ូមនឹងគេណា។

កៈ ចាំ!

ខៈ គេមានប៊ូមចង់គ្រាប់ទាំងផ្ទះហើយមកដល់ពេលរាល់តែថ្ងៃ។

កៈ ហឹមចាំយាយ!

ខៈ ហឹស! វេទនាណាស់ចៅ ។

កៈ ចឹងយាយអត់មានពាក្យអីផ្តាំទៀតនោះទេយាយមានតែប៉ុណ្ណឹង?

ខៈ មានខ្ញុំមាន ខ្ញុំចង់បានដូចថា កូនចៅនុង គេបានគិតអីបានបន្តិចបន្តួចគេបានជូនអីមក ខ្ញុំយកមកកសាងអីនេះមក ខ្ញុំបានមកធ្វើកន្លែងខ្ញុំមកនៅ ដល់ពេលខ្ញុំបានងាប់ទៅនុងគឺថាអោយខ្ញុំនេះបានស្រួល ហើយអោយខ្ញុំបាននៅហើយ ខ្ញុំនេះចង់តែចឹង កុំតែអាលែងនេះ វាមានកាហឹងកាហុងចឹងហើយ ដល់ពេលខ្ញុំបានងាប់ទៅវាអត់មានអីកប់ខ្ញុំមិននៅនោះទេ។

កៈ ហឹម

ខៈ ខ្ញុំគ្មានបានគិតអីទៀតនោះទេ ខ្ញុំគ្រាន់តែថាចង់បានអីអោយតែស្រួលនៅពេលកន្លែងដេកនោះតទៅទៀតនោះទេ។

កៈ ហឹម

ខៈ ហើយបានអាយុបាន៩១ហើយចឹងតើមានបានអាយុនុងដល់ប៉ុន្មានទៀត ចៅឯងបានគិតទៅមើល?

កៈ ហឹម!

ខៈ ចឹងបានថា បើសិនជាបាននៅដល់អាយុបាន១០០ចឹងទៅក៏វាបាន គេមាននៅដល់១០០តែថាខ្ញុំនេះបាននៅដល់ឬក៏មិនដល់។

កៈ ហឹម តែថាមកដល់ពេលសព្វថ្ងៃនេះខ្ញុំមិនបានឈឺអីនោះទេ ខ្ញុំមិនបានឈឺនោះទេ ក៏ប៉ុន្តែយាយនិយាយនេះ មិនដឹងថាដល់ឬក៏មិនបានដល់ វាមានភ្លេចខ្លះ វាមានវង្វេងខ្លះទៅហើយ វាមានចាំខ្លះ ហើយទៅវាមានច្រលំអីខ្លះចឹងទៅណា ព្រោះអីវាចាស់ណាស់ទៅហើយ។

កៈចាំយាយចឹងជាចុងក្រោយយាយមានពាក្យពេចន៍អ្វី ដើម្បីបន្ថែមទៀតដែលឬក៏អត់ឬក៏មានតែប៉ុណ្ណឹងនោះទេយាយ?

ខៈ ខ្ញុំមានពាក្យពេចន៍អីគេនិយាយ ទាល់តែថាចៅបានសួរនោះទៅបានដឹង។

ក៖ ចាំដូចថាយាយបានចង់ផ្ដែផ្ដាំដល់កូនចៅរបស់យាយ ជាពិសេសអ្នកនៅជំនាន់ក្រោយណា ដែលគេបានស្ដាប់សំលេងយាយនុង អោយគេបានធ្វើយ៉ាងណាដែរ?

ខ៖ ខ្ញុំពេលណា ដែលខ្ញុំបានប្រាប់ ចៅណាវាចេស វាចេស ចៅណាវាមានធ្វើ វាបានធ្វើចេះធ្វើចុះ វាមានបានស៊ីអីដូចជាអញដែរ ចឹងថាកុំគិតថាវាមានបានគិតអីពីគេ! ចឹងមានបានគេនិយាយដែស?

ក៖ ចាំ!

ខ៖ យាយនុង១នោះក៏បានយ៉ាប់ដែរនោះ។

ក៖ ចាំចឹងអរគុណដល់លោកយាយដែរដែលសំរាប់ការសម្ភាសនៅក្នុងថ្ងៃនេះចឹងណាលោកយាយ?

ខ៖ ចាំ!

ក៖ ចាំចឹងបើសិនជាខាងសាលារៀន BYUនៅខាងសហរដ្ឋអាមេរិកដែលគេមានគំរោង១ឈ្មោះការសម្ភាសផ្ទាល់មាត់របស់ប្រជាជនកម្ពុជា ដែលយើងមានគេហៈទំព័រ www.cambodianoral history.byu.edu ដើម្បីដាក់សម្លេងរបស់លោកយាយនៅក្នុងគេហៈទំព័រ១ហ្នឹងហើយនិងបានសូមថតរូបរបស់លោកយាយ១ដែរ ដើម្បីអោយកូនចៅជំនាន់ក្រោយគេបានចូលទៅស្ដាប់ហើយនឹងបានមើលរូបរបស់លោកយាយ១ផ្ទាល់ណា តើលោកយាយអនុញ្ញាតអោយគេបានដាក់ដែរឬទេ?

ខ៖ ចៅមើលណា ថតនៅឯណាចៅ?

ក៖ រូបថតដែលបានថតលោកយាយមុននឹងណា?

ខ៖ ចាំ

ក៖ ចឹងលោកយាយបានអនុញ្ញាតណា! ចាំចឹងបើសិនជាអនុញ្ញាតលោកយាយឆ្លើយថាបាន?

ខ៖ បាន!

ក៖ ចាំ!អរគុណលោកយាយ!

ខ៖ ចាំ!